ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
31 / 03 / 2015
ម៉ោង (Time/Heure) : 09:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé
SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**សាធារណៈ / Public**

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៥

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី÷** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន÷** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ÷** **សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨៧(៤) ពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ដោយភ្ជាប់ជាមួយឧបសម្ព័ន្ធ ក សម្ងាត់**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើពីសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សំណើ") ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៥ សុំឱ្យបញ្ចូលព័ត៌មានបន្ថែមពីដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ធ្វើជាភស្តុតាង និង កោះហៅគាត់ឱ្យមកផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលសវនាការស្តីពីសហករណ៍ត្រាំកក់ (ឯកសារ E344 កថាខណ្ឌ ១-២ និង ត្រង់ទំព័រ ៨ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ក សម្ងាត់ ឯកសារ E344.1)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា ព័ត៌មានបន្ថែម ចុះថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១៥ បានបំពេញលក្ខខណ្ឌក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង (ឯកសារ E344 កថាខណ្ឌ ៩)។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងបន្ថែមទៀតថា ឧបសម្ព័ន្ធ ក សម្ងាត់ មានព័ត៌មានពាក់ព័ន្ធទៅនឹងអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទ ដែលជាដំណើរទស្សនកិច្ចរបស់មេដឹកនាំបួន

រូប ដែលរួមទាំង នួន ជា និង ខៀវ សំផន ដូចដែលបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ ក (ឯកសារ E344 កថា-ខណ្ឌ ១០-១១)។ សហមេធាវីនាំមុខបានបន្ថែមថា "ព័ត៌មានដ៏សំខាន់មួយផ្នែក" នេះ នឹងមិនអាចទទួលបានទេប្រសិនណាបើគ្មានសក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី D22/2500 (ឯកសារ E344 កថាខណ្ឌ ១៣)។ សហព្រះរាជអាជ្ញាបានលើកឡើងថា ព័ត៌មានដែលដើម បណ្តឹងរដ្ឋប្បវេណី D22/2500 ផ្តល់ឱ្យមានភាពពាក់ព័ន្ធ និងថា គាត់គួរតែត្រូវបានកោះហៅឱ្យមកធ្វើសក្ខីកម្ម ដោយសារតែការរៀបរាប់របស់គាត់ពាក់ព័ន្ធទៅនឹងអំពើ និងអាកប្បកិរិយារបស់ជនជាប់ចោទ (ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៥)។ គ្មានក្រុមមេធាវីការពារក្តីណាមួយជំទាស់ទៅនឹងការបង្ហាញខ្លួនរបស់ដើមបណ្តឹងរូបនេះនៅក្នុងសវនាការទេ។ នៅថ្ងៃទី១៩ ខែ មីនា ឆ្នាំ ២០១៥ មន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងទៅភាគីតាមអ៊ីម៉ែលថា អង្គជំនុំជម្រះសាលាដំបូងបានឯកភាពតាមសំណើសុំស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ (E344/1.1)។ ខាងក្រោមនេះគឺជាសម្អាងហេតុរបស់អង្គជំនុំជម្រះ។

២. អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧(៣) ខាងលើ។ វិធាន ៨៧(៤) ក៏តម្រូវឱ្យភាគីដែលស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា ភស្តុតាងដែលបានស្នើសុំនោះ ពុំមានអត្ថិភាព ឬពុំអាចរកបាននៅមុនពេលការចាប់ផ្តើមការជំនុំជម្រះ ទោះបីជាបានខិតខំស្វែងរកដោយសមស្របហើយក៏ដោយ។ ទោះជាបែបនេះក្តី នៅក្នុងករណីមួយចំនួនអង្គជំនុំជម្រះបានទទួលយកភស្តុតាងមួយចំនួន ដែលមិនបានបំពេញលក្ខខណ្ឌទាំងនេះទេ ដូចជាករណីមួយចំនួន ដែលភស្តុតាងទាក់ទងទៅនឹងឯកសារដែលបានដាក់នៅចំពោះមុខអង្គជំនុំ-ជម្រះរួចហើយ ហើយភស្តុតាងដែលបានស្នើសុំនោះគឺជាភស្តុតាងដោះបន្ទុក ដែលត្រូវធ្វើការវាយតម្លៃ ដើម្បីជៀសវាងកុំឱ្យមានភាពអយុត្តិធម៌ ឬ ក្នុងករណីដែលភាគីផ្សេងទៀតមិនបានជំទាស់ទៅនឹងភស្តុតាងនោះ (ឯកសារ E276/2 យោងទៅឯកសារ E190 និង E172/24/5/1)។

៣. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ភស្តុតាងថ្មីនេះមិនអាចរកបានទេ មុនពេលចាប់ផ្តើមការជំនុំជម្រះ ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណី D22/2500 មិន

បានផ្តល់ព័ត៌មាននេះ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ (ឯកសារ E344 កថាខណ្ឌ ១៤)។ សហមេធាវីនាំមុខបានលើកឡើងបន្ថែមទៀតថា ពួកគាត់បានខិតខំស្វែងរកដោយស្របស្របរួចហើយ ព្រោះថាពួកគាត់បានទទួលព័ត៌មានបន្ថែមពីដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ភ្លាមៗបន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ "សម្តែងពីចេតនាក្នុងការបង្ហាញព័ត៌មាននេះ ហើយអាចមកចូលរួមក្នុងកិច្ចប្រជុំជាមួយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី" (ឯកសារ E344 កថាខណ្ឌ ១៤)។

៤. អង្គជំនុំជម្រះសាលាដំបូងសង្កេតឃើញថា ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ត្រូវបានដាក់នៅថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១០ មុនពេលការចាប់ផ្តើមជំនុំជម្រះ។ បើទោះបីជាពាក្យសុំនេះមិនមានភស្តុតាងដែលត្រូវវិនិច្ឆ័យស្តីអំពីអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទក៏ដោយ ក៏ពាក្យសុំនេះពិតជាបានបង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានធ្វើការនៅក្នុងកងពិសេសក្នុងស្រុកត្រាំកក់ ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គជំនុំជម្រះយល់ឃើញថា ព័ត៌មានពាក់ព័ន្ធទៅនឹងអំពើ និង អាកប្បកិរិយារបស់ជនជាប់ចោទនេះ គួរតែត្រូវបានរកឃើញនាពេលក្រោយមក បន្ទាប់ពីបានខិតខំស្វែងរកដោយសមស្រប តាមរយៈការសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សហមេធាវីនាំមុខមានកាតព្វកិច្ចស្នើសុំឱ្យទទួលយកភស្តុតាងនេះឱ្យបានទាន់ពេលវេលា យ៉ាងហោចណាស់នៅមុនការចាប់ផ្តើមជំនុំជម្រះលើសំណុំរឿង ០០២/០២ ដោយសារតែសំណុំរឿងនេះមានបញ្ចូលអង្គហេតុស្តីពីសហករណ៍ត្រាំកក់។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនបានស្នើសុំទេ រហូតមកទល់ខែ មីនា ឆ្នាំ ២០១៥ នេះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចថា សហមេធាវីនាំមុខមិនបានខិតខំស្វែងរកដោយសមស្របទេ និងថា សំណើនេះមិនត្រូវបានដាក់ទាន់ពេលវេលា។

៥. ទោះជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះយល់ថា ការទទួលយកព័ត៌មានបន្ថែមធ្វើជាភស្តុតាង និង ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី D22/2500 គឺជាប្រយោជន៍យុត្តិធម៌។ អង្គជំនុំជម្រះកត់សម្គាល់បន្ថែមទៀតថា ដើមបណ្តឹងរដ្ឋប្បវេណី D22/2500 បានលើកឡើងនៅក្នុងព័ត៌មានបន្ថែមថា គាត់បានឃើញ ខៀវ សំផន និង នួន ជា មួង នៅកន្លែងធ្វើការរបស់គាត់ ហើយថា ប្រធានកងរបស់គាត់បានប្រាប់គាត់ថា ខៀវ សំផន និង នួន ជា ជានរណា (ឯកសារ E344.1)។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត 2-TCCP-238 បានផ្តល់សក្ខីកម្មថា គាត់បានឃើញ ខៀវ សំផន និង នួន ជា នៅសហករណ៍ស្រុកត្រាំកក់ (ប្រតិចារឹក ចុះថ្ងៃទី

២៦ ខែ មករា ឆ្នាំ ២០១៥ ទំព័រ ៥១-៥២)។ អាស្រ័យហេតុនេះ ជាប្រយោជន៍យុត្តិធម៌ ត្រូវវាយតម្លៃទៅលើការរៀបរាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី D22/2500 អំពីវត្តមានរបស់ជនជាប់ចោទទាំងពីរនៅសហករណ៍ រួមនឹងឯកសារផ្សេងទៀតដែលបានដាក់នៅចំពោះមុខអង្គ-ជំនុំជម្រះរួចហើយ។

៦. ដោយយល់ឃើញថា ការទទួលយកព័ត៌មានបន្ថែមនេះធ្វើជាភ័ស្តុតាង និង ការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី D22/2500 នៅក្នុងសវនាការ គឺជាប្រយោជន៍យុត្តិធម៌ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងឯកភាពតាមសំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី និង ដាក់រហស្សនាម 2-TCCP-980 ទៅដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

៧. ដោយសារតែដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មទៅលើតែបញ្ហាមួយចំនួនតូចពាក់ព័ន្ធនឹងវត្តមានរបស់ជនជាប់ចោទនៅស្រុកត្រាំកក់នោះ អង្គជំនុំជម្រះផ្តល់រយៈពេលសរុបកន្លះថ្ងៃនៃសវនាការដល់ភាគីដើម្បីស្តាប់សក្ខីកម្ម 2-TCCP-980។

៨. សេចក្តីសម្រេចនេះជាការឆ្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះចំពោះសំណើ E344។